ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល
លេខៈ ១៧១/២៣ អអរ

# សេចក្តីប្រកាសព័ត៌មាន
## លទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី "ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តស្វាយរៀង"

នាព្រឹកថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តស្វាយរៀង»** ដែលមានវាគ្មិនចូលរួមគឺៈ

- **ឯកឧត្តម ម៉ែន វិបុល អភិបាលនៃគណៈអភិបាលខេត្តស្វាយរៀង**
- **មន្ទីរអង្គភាពជំនាញជុំវិញរដ្ឋបាលខេត្តស្វាយរៀង**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងពន្យល់ និងផ្សព្វផ្សាយដល់សាធារណជនឱ្យបានជ្រាបច្បាស់អំពី យន្តការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងភាពជោគជ័យដែលរដ្ឋបាលខេត្តស្វាយរៀង ខិតខំប្រឹងប្រែងអនុវត្ត ព្រមទាំងសម្រេចបានសមិទ្ធផលវិជ្ជមាន ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ប្រកបដោយថាមពលរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

## I. ស្ថានភាពទូទៅ

ខេត្តស្វាយរៀង ចែកចេញជា ២ក្រុង ៦ស្រុក ៦៨ឃុំ ១២សង្កាត់ និង៦៩០ភូមិ មានប្រជាពលរដ្ឋសរុបចំនួន ៦៧៤.៦៣៥នាក់ ស្មើនឹង ១៦០.៦១១គ្រួសារ។ សេដ្ឋកិច្ចខេត្តមានទំហំប្រមាណ ១.០៧៤,៥លានដុល្លារអាមេរិក ស្មើនឹង ៤% នៃសេដ្ឋកិច្ចជាតិ មានកំណើន ៥,៦% បើធៀបនឹងឆ្នាំ ២០២១ ក្នុងនោះបានចូលរួមចំណែកពីវិស័យកសិកម្ម៤៣,៧៦% វិស័យឧស្សាហកម្ម៣៨,១២% និងវិស័យសេវាកម្ម ១៨,១២%។ ចំណូលសម្រាប់មនុស្សម្នាក់ មានប្រមាណ ១.៥៩៤.៩ដុល្លារអាមេរិក។

## II. សមិទ្ធផលការងារ

ក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ(២០១៨-២០២២) សមិទ្ធផលការងារសំខាន់ៗ ដែលសម្រេចបានរួមមាន៖

- **វិស័យគាំពារសង្គម៖** រដ្ឋបាលខេត្ត បានអនុវត្តនូវគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាល ដោយបានឧបត្ថម្ភជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ចំនួន ៣៣.៧០៦គ្រួសារ ស្មើនឹងទឹកប្រាក់ ១២៣.៤២៥.០៦០.០០០រៀល, ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ២៩.២២៨នាក់ ស្មើនឹងថវិកា ១.៦៥៩.៥២០.០០០រៀល, គ្រួសារងាយរងហានិភ័យដោយសម្ពាធអតិផរណា ៤៦.១២៤គ្រួសារ ស្មើនឹង ៥.៨៥២.៤៥៣.២០០ រៀល និងគ្រោះទឹកជំនន់ចំនួន ៣៧០.៩៤៤.០០០រៀល ព្រមទាំងបានឧបត្ថម្ភ ជូនជនពិការមានភាពក្រីក្រតាមសហគមន៍នៅចំនួន ២.១០០នាក់ សរុបទឹកប្រាក់ចំនួន ៤៣៥.៩៦០.០០០រៀល។
- **វិស័យកសិកម្ម៖** ជាវិស័យអាទិភាពមួយ ដែលជាប្រភពចំណូលទ្រទ្រង់សេដ្ឋកិច្ចខេត្ត និងប្រជាជនទាំងមូល ដោយខេត្តមានផ្ទៃដីផលិតកម្មកសិកម្ម សរុប ២០៥.៤៧៦ហិកតា។ ដោយសារការរីកចម្រើនផ្នែកបច្ចេកទេស និងបច្ចេកវិទ្យា ប្រជាពលរដ្ឋ ប្រកបការងារបង្កបង្កើនផលតាមបែបទំនើបកម្មកសិកម្ម ធ្វើឱ្យទិន្នផលកសិកម្មដែលទទួលបាន ការកើនឡើងលើសផែនការជារៀងរាល់ឆ្នាំ។ ចំពោះប្រភពទឹកសំខាន់ បម្រើឱ្យការប្រើប្រាស់ និងស្រោចស្រពដំណាំកសិកម្មមាន ០៣គឺ ទន្លេកំពង់ត្រាច ទន្លេវៃគោ និងព្រែកព្រំដែនកម្ពុជា-វៀតណាម ព្រមទាំងមានព្រែកចំនួន ១១ព្រែក និងមានអូរចំនួន ៣៩អូរ និងកំពុងបន្តស្តារ សាងសង់បន្ថែមទៀត។
- **ការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ៖** ដោយមានការចូលរួមសហការជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ រួមទាំងប្រជាពលរដ្ឋទាំងអស់ និងការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព បានធ្វើសន្តិសុខសណ្តាប់ធ្នាប់សាធារណៈមានលក្ខណៈល្អប្រសើរ ជានាដល់ការរស់នៅរបស់ប្រជាពលរដ្ឋ ប្រកបដោយសេចក្តីសុខសាន្ត ជាពិសេសជានាដល់ដំណើរការអភិវឌ្ឍខេត្ត ឱ្យមានរីកចម្រើន សំដៅលើកកម្ពស់សុខុមាលភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ឱ្យកាន់តែប្រសើរឡើង។ ជាលទ្ធផលក្នុងចលនាប្រលងប្រណាំងភូមិ-ឃុំមានសុវត្ថិភាព ឃុំ-សង្កាត់ ដែលទទួលបាន ចំណាត់ថ្នាក់លេខ១ ចំនួន ៧៨ ឃុំ-សង្កាត់ លេខ២ ចំនួន ០២ឃុំ។
- **ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ៖** រដ្ឋបាលខេត្ត បានខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ សំដៅតភ្ជាប់ផ្លូវគ្រប់ទីរួមស្រុក ទៅកាន់គ្រប់ឃុំ-សង្កាត់ និងទីជនបទ សម្រួលដល់ការដឹកជញ្ជូនទំនិញ និងការធ្វើដំណើររបស់ប្រជាពលរដ្ឋកាន់តែងាយស្រួល។ ខេត្តមានផ្លូវជាតិ ផ្លូវខេត្តសរុប ៥៥ខ្សែ ផ្លូវក្រុង ៦០ខ្សែ និងផ្លូវជនបទ ៧៦៤ខ្សែ។ ជាមួយគ្នានេះ ការថែទាំ

សោកណ្ឌាភាពទីក្រុង ត្រូវបានរៀបចំ និងកែលម្អជាបន្តបន្ទាប់ ក្នុងនោះ ខេត្តស្វាយរៀង ជាខេត្តទីមួយ ដែលបានប្រកាសជាខេត្តបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល និងត្រូវបានប្រកាសជាខេត្តអស់មីនផងដែរ។ ដោយឡែក ការផ្គត់ផ្គង់ទឹកស្អាត និងអគ្គិសនី ត្រូវបានលើកកម្ពស់ ដោយបច្ចុប្បន្ននេះ ប្រជាពលរដ្ឋទូទាំងខេត្ត មានទឹកស្អាតប្រើប្រាស់ប្រមាណ ៩៩,៤% និងបណ្តាញអគ្គិសនីត្រូវបានគ្របដណ្តប់ និងតភ្ជាប់សឹងតែគ្រប់ភូមិទាំងអស់ ពោលគឺនៅសល់តែ ១៩ភូមិប៉ុណ្ណោះ ដែលគ្មានបណ្តាញអគ្គិសនី។

- **វិស័យទេសចរណ៍៖** រមណីយដ្ឋានសំខាន់ៗក្នុងខេត្តរួមមាន រមណីយដ្ឋានទេសចរណ៍ប្រាសាទព្រៃបាសាក់ រមណីយដ្ឋានបុរាណទួលព្រៃយាយដូន ប្រាសាទជាហោ រមណីយដ្ឋានធម្មជាតិព្រៃគគីរ រមណីយដ្ឋានធម្មជាតិទឹកវិល ព្រមទាំងមានកន្លែងកម្សាន្តទេសចរណ៍ក្នុងក្រុងមួយចំនួនទៀត។ ដើម្បីចូលរួមចំណែកក្នុងការលើកកម្ពស់វិស័យទេសចរណ៍ ខេត្តក៏បានរៀបចំនូវព្រឹត្តិការណ៍មួយចំនួនដូចជា ពិធីប្រណាំងទូក សង្ក្រាន្តស្វាយរៀង ដែលកន្លងមកបានទាក់ទាញភ្ញៀវទេសចរមកលេងកំសាន្តរាប់សែននាក់ ជាពិសេសកម្មវិធីសង្ក្រាន្តស្វាយរៀង (ផ្អែកតំបន់ត្រជាក់ចិត្ត) ខេត្តបន្តធ្វើរហូតដល់ចុងខែមេសា។
- **ការផ្តល់សេវាសាធារណៈ៖** តាមរយៈការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ខេត្តបានរៀបចំ និងដាក់ឱ្យដំណើរការនូវអង្គភាពច្រកចេញចូលតែមួយខេត្ត ការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក និងឃុំ-សង្កាត់ សំដៅជានាបាននូវប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព និងគណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។ យន្តការច្រកចេញ-ចូលតែមួយបានផ្តល់សេវារដ្ឋបាល សរុបចំនួន ២០៦.០២៣សេវា ប្រាក់ចំណូលទទួលបានសរុបចំនួន ១៤.៣៥៦.០៩៥.២៧៦រៀល។
- **ការអភិវឌ្ឍធនធានមនុស្ស៖** ការងារអភិវឌ្ឍ និងបណ្តុះបណ្តាលធនធានមនុស្សត្រូវបានជំរុញ និងលើកកម្ពស់។ រដ្ឋបាលខេត្ត បានខិតខំពង្រឹង និងពង្រីកឱ្យមានសាលារៀននៅគ្រប់ភូមិបណ្តាទាំងអស់ (សាលារត់កេសិស្ស)។ បច្ចុប្បន្ននេះ ខេត្តមានអគារសិក្សា ៩៦២ខ្នង សាលាមត្តេយ្យរដ្ឋ ១៧៥សាលា ក្នុងនោះសាលាមត្តេយ្យដាច់ដោយឡែកមានចំនួន ០៦សាលា មត្តេយ្យសហគមន៍ ៣០៤កន្លែង សាលាបឋមសិក្សា ២៦២សាលា អនុវិទ្យាល័យ ៥៣សាលា វិទ្យាល័យ ២១សាលា សាលាគរុកោសល្យនិងវិក្រឹត្យការ ០១កន្លែង និងមានសាកលវិទ្យាល័យ ០១កន្លែង។ ក្នុងឆ្នាំសិក្សា ២០២១-២០២២ មានសិស្សប្រលងជាប់សរុប ២.៨៨០នាក់ ស្មើនឹង ៧៥% ក្នុងនោះ ស្រី ១.៦៣៤នាក់ ស្មើនឹង ៥៦,៧៣%។
- **វិស័យការងារ ពាណិជ្ជកម្ម និងឧស្សាហកម្ម៖** ដើម្បីរួមចំណែកលើកកម្ពស់ជីវភាពរស់នៅ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ខេត្តបានខិតខំទាក់ទាញឱ្យមានការវិនិយោគជាបន្ត

បន្ទាប់ ដោយបច្ចុប្បន្ននេះ មានតំបន់សេដ្ឋកិច្ចពិសេស ចំនួន ១២កន្លែង និងកំពុងដំណើរការ ចំនួន ៩កន្លែង និងសហគ្រាសមួយចំនួនទៀតស្ថិតនៅក្រៅតំបន់សេដ្ឋកិច្ច ពិសេស ដែលមាន រោងចក្រ សហគ្រាសសរុបមានចំនួន ២៦២កន្លែង ផ្តោតសំខាន់ក្នុងការផលិតសម្លៀកបំពាក់ ការដំឡើងរថយន្ត ផលិតកង់ នាឡិកា សំបកកង់ឡាន ម៉ាស់ បរិក្ខាសុខាភិបាល អំពូលភ្លើង គ្រង់ស្វូអេគ្គិសនី ផ័ត្រ គ្រឿងសង្ហារឹម បារី តុក្កតា សាឡុង និងវត្ថុអនុស្សាវរីយ៍ផ្សេងៗ សម្រាប់ គោលដៅនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាម៉េរិក សហភាពអឺរ៉ុប ប្រទេសចិន និងប្រទេសផ្សេងៗ ទៀត បានបង្កើតការងារធ្វើជូនប្រជាពលរដ្ឋប្រមាណជាង ៩ម៉ឺននាក់។

## III. ទិសដៅការងារបន្ត

រដ្ឋបាលខេត្ត បានប្តេជ្ញាបន្តថែរក្សា ពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាព សង្គមឱ្យបានកាន់តែរឹងមាំ និងពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ជានាបាននូវការបង្ការ ទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសគ្រប់ប្រភេទ។ ខិតខំជំរុញការអភិវឌ្ឍខេត្ត ឱ្យសម្រេចបានលទ្ធផលល្អ និងបន្តយកចិត្តទុកដាក់ដោះស្រាយបញ្ហាប្រឈមនានានៅមូលដ្ឋាន និង ទទួលយកនូវសំណើ សំណូមពររបស់ប្រជាពលរដ្ឋ ជាពិសេសបញ្ហាទំនាស់ដីធ្លី និងវិវាទនានានៅ មូលដ្ឋាន ដោយផ្អែកតាមនីតិវិធីច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមាន។ បន្តជំរុញការងារបង្កបង្កើនផល ការងារផលិតកម្មកសិកម្ម ដោយផ្តល់ជំនាញបច្ចេកទេស កសិកម្មដល់ប្រជាកសិករ ជាពិសេសជំរុញ ការប្រឡងប្រណាំងចលនាភូមិមួយ ផលិតផលមួយ និងជំរុញផ្សព្វផ្សាយ អំពីការអប់រំបណ្តុះបណ្តាល វិជ្ជាជីវៈ និងបច្ចេកទេស ដើម្បីផ្តល់ជំនាញដល់ប្រជាពលរដ្ឋ ដើម្បីងាយស្រួលក្នុងការរកការងារធ្វើ ក៏ដូចជាបង្កើតមុខរបរផ្ទាល់ខ្លួនបង្កើនប្រាក់ចំណូលគ្រួសារ ព្រមទាំងលើកទឹកចិត្ត និងផ្តល់បច្ចេកទេស កសិកម្ម សំដៅលើកកម្ពស់ការងារផលិតកម្មពិពិធកម្មកសិកម្ម ដល់ប្រជាកសិករ ដើម្បីធ្វើការផ្គត់ផ្គង់ តម្រូវការក្នុងស្រុក និងការនាំចេញ ជួយសម្រួលដោះស្រាយការងារធ្វើ និងលើកកម្ពស់ជីវភាពរស់នៅ របស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង។៚

ថ្ងៃព្រហស្បតិ៍ ៨កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣